**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ: 77 សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ, ថ្ងៃទី20 ខែ ឧសភា ឆ្នាំ ២០០២

# សេចក្តីកំណត់
## ស្តីពី
## តួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និង របៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សស្រុក-ខណ្ឌ

- យោងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស
- ផ្អែកតាមសំណូមពរ នៃភារកិច្ចនយោបាយរបស់គណបក្សនាតំណាក់កាលបច្ចុប្បន្ន
- យោងមតិឯកភាពរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល កំណត់**

អំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និង របៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្ស ស្រុក-ខណ្ឌ ដូចខាងក្រោម ៖

### I - តួនាទី ភារកិច្ច សិទ្ធិ

### ក- អំពីតួនាទី

គណៈកម្មាធិការគណបក្ស ស្រុក-ខណ្ឌ គឺជាអង្គការដឹកនាំរបស់គណបក្សនៅក្នុងចន្លោះពីមហាសន្និបាតគណបក្ស ស្រុក-ខណ្ឌមួយទៅមហាសន្និបាតគណបក្សស្រុកខណ្ឌមួយទៀត ដោយស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សខេត្ត-ក្រុង មានភារៈទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការគណបក្ស ខេត្ត-ក្រុង និងគណបក្សថ្នាក់ខ្លួនក្នុងការដឹកនាំចាត់តាំងអនុវត្ត និងត្រួតពិនិត្យគ្រប់វិស័យការងាររបស់គណបក្សដើម្បីសំរេចភារកិច្ចនយោបាយដែលគណបក្សថ្នាក់លើបានកំណត់ និងសេចក្តីសំរេចចិត្តរបស់មហាសន្និបាតគណបក្សថ្នាក់ខ្លួន ។

### ខ- អំពីភារកិច្ច

ភារកិច្ចសំខាន់ៗរបស់គណៈកម្មាធិការគណបក្ស ស្រុក-ខណ្ឌ រួមមាន ៖

១- ក្តាប់ជាប់លក្ខន្តិកៈ កម្មវិធីនយោបាយរបស់គណបក្ស គោលការណ៍ សេចក្តីសំរេចចិត្ត សេចក្តីណែនាំនានារបស់គណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សខេត្ត-ក្រុង និងសេចក្តីសំរេចចិត្តនៃមហាសន្និបាតគណបក្សស្រុក-ខណ្ឌ

ដើម្បីកំណត់ទិសដៅ ភារកិច្ច គោលការណ៍ និងវិធានការចាត់តាំងអនុវត្តអោយបានសមស្របតាមសភាពការណ៍ជាក់ស្តែងរបស់ស្រុក-ខ័ណ្ឌ ព្រមទាំងដឹកនាំគ្រប់គណៈកម្មាធិការគណបក្សមូលដ្ឋាន និងអង្គការចាត់តាំងគណបក្សចំណុះ អោយអនុវត្តបានសំរេចជោគជ័យ ។

២- ដឹកនាំពង្រឹងរបៀបរបបការងារគណបក្ស និងរចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្សនៅតាមការិយាល័យផ្នែកនានាជុំវិញ ស្រុក-ខ័ណ្ឌ និងបណ្តាមូលដ្ឋានចំណុះ។ គ្រប់គ្រង កសាង ពង្រីកសមាជិកគណបក្ស និង ដឹកនាំការងារចលនាមហាជនសំដៅប្រមូលផ្តុំបាននូវកំលាំងដ៏ទូលំទូលាយចូលរួមរាល់សកម្មភាពរបស់គណបក្ស គាំទ្រ អនុវត្តកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស ។

៣- ដឹកនាំក្រើនរំលឹកមន្ត្រីគណបក្ស ដែលត្រូវបានប្រគល់ភារកិច្ចអោយទទួលបន្ទុកការងារនៅតាមបណ្តាការិយាល័យ ផ្នែកនានាជុំវិញស្រុក-ខ័ណ្ឌ នៅតាមបណ្តាឃុំ-សង្កាត់ មូលដ្ឋាននិងអង្គភាពនានាដែលស្ថិតក្នុងភូមិសាស្ត្រខ្លួនអោយខិតខំអនុវត្តល្អនូវតួនាទី ភារកិច្ចរបស់ខ្លួន ព្រមទាំងយកចិត្តទុកដាក់អនុវត្តល្អការងារគណបក្ស និងពង្រឹងប្រជាប្រិយភាពរបស់គណបក្សនៅមូលដ្ឋាន ។

៤ - ថែរក្សា និងពង្រីកសមិទ្ធផលនានារបស់គណបក្ស ដែលបានកសាងនៅមូលដ្ឋាន សំរាប់ប្រើប្រាស់ជាផលប្រយោជន៏ដល់ប្រជាជន ។

**គ- សិទ្ធិ**

គណៈកម្មាធិការគណបក្ស ស្រុក-ខ័ណ្ឌ មានសិទ្ធិ :

១- ដឹកនាំ ណែនាំនិងត្រួតពិនិត្យការអនុវត្តន៏រាល់ភារកិច្ចការងាររបស់គណបក្សក្នុងក្របខ័ណ្ឌ ស្រុក- ខ័ណ្ឌរបស់ខ្លួន ។

២- សំរេចតែងតាំង តំលើងឋានៈ ផ្លាស់ប្តូរភារកិច្ច លើកសរសើរ និងដាក់វិន័យចំពោះមន្ត្រីគណបក្ស ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ ។

៣- សំរេចការរៀបចំមន្ត្រីគណបក្សនៃបណ្តាគណៈ ផ្នែកការិយាល័យជុំវិញគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ចាប់ពីថ្នាក់អនុប្រធានគណៈ អនុប្រធានផ្នែក អនុប្រធានការិយាល័យចុះ ។

៤- សំរេចការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សបណ្តោះអាសន្នឃុំ-សង្កាត់ គណៈកម្មាធិការគណបក្សបណ្តោះអាសន្នមូលដ្ឋានចំណុះ ចាប់ពីថ្នាក់អនុប្រធានចុះ ។

៥ - សំរេចបង្កើត រំសាយ និងរៀបចំបណ្តោះអាសន្នសមាសភាពដឹកនាំសាខាគណបក្ស ។

៦- លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ដើម្បីសុំសេចក្តីសំរេចអំពីការងារមន្ត្រីគណបក្សក្នុងក្របខ័ណ្ឌ ស្រុក-ខ័ណ្ឌ ដែលស្ថិតក្នុងសមត្ថកិច្ចសំរេចរបស់គណបក្សខេត្ត-ក្រុង អំពីការរៀបចំបណ្តោះអាសន្នគណៈកម្មាធិការត្រួតពិនិត្យ គណៈកម្មាធិការហិរញ្ញវត្ថុគណបក្សស្រុក-ខ័ណ្ឌ និងអំពីការងារគណបក្សដែលមានការស្មុគស្មាញ

និងសំណូមពររបស់សមាជិកគណបក្ស មហាជនប្រជាជននៅមូលដ្ឋានដែលគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ មិនអាចដោះស្រាយបាន ។

៧ - ចូលរួមយោបល់ អំពីការរៀបចំមន្ត្រីគណបក្សចូលកាន់មុខនាទីក្នុងការិយាល័យជំនាញនានាជុំវិញស្រុក-ខ័ណ្ឌ ។

II - **រចនាសម្ព័ន្ធ អង្គការចាត់តាំង**

**ក-អំពីរចនាសម្ព័ន្ធ**

រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ត្រូវមានមន្ត្រីវ័យចាស់ វ័យក្មេង ជានារីភេទ ជាជនជាតិភាគតិច ( នៅមូលដ្ឋានដែលមានជនជាតិភាគតិចច្រើន ) ជាមន្ត្រីគណបក្សដែលមានលក្ខណៈសម្បត្តិល្អប្រពៃ ទស្សនៈគោលជំហរនយោបាយរឹងមាំ ប្រកបដោយគុណធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន មានលទ្ធភាព និង សមត្ថភាពការងារការងារគណបក្សដែលបានប្រគល់ជូន ។

ការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម :

- គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ រួមមានសមាសភាពមន្ត្រីគណបក្សជាអភិបាល អភិបាលរងស្រុកខ័ណ្ឌ មន្ត្រីមានបទពិសោធន៍ និងមានឥទ្ធិពលល្អក្នុងការដឹកនាំ ប្រធានគណៈចាត់តាំង ប្រធានផ្នែកឃោសនាអប់រំ ប្រធានគណៈត្រួតពិនិត្យ ប្រធានគណៈហិរញ្ញវត្ថុ ប្រធានការិយាល័យគណបក្សស្រុក-ខ័ណ្ឌ មន្ត្រីដឹកនាំកងកំលាំងប្រដាប់អាវុធ មន្ត្រីដឹកនាំសាលាស្រុក-ខ័ណ្ឌ ការិយាល័យ ផ្នែកមួយចំនួនជុំវិញស្រុក-ខ័ណ្ឌ បណ្តាប្រធានគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន ។

- គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ រួមមានសមាសភាពមន្ត្រីគណបក្សក្នុងជួរអភិបាល អភិបាលរងស្រុក-ខ័ណ្ឌ មន្ត្រីមានបទពិសោធន៍ និង មានឥទ្ធិពលល្អក្នុងការដឹកនាំ ប្រធានបណ្តាគណៈ ផ្នែក និងការិយាល័យជុំវិញគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ មន្ត្រីដឹកនាំកងកំលាំងប្រដាប់អាវុធ ។

**ខ-អំពីបរិមាណ**

បរិមាណសមាជិកគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ត្រូវបានកំណត់ដោយផ្អែកលើស្រុក-ខ័ណ្ឌ ធំ ឬមធ្យម និងតូច ដែលចែកជាពីរប្រភេទរួមមាន :

- ប្រភេទស្រុក-ខ័ណ្ឌធំ គឺស្រុក-ខ័ណ្ឌ ជាទីប្រជុំជនសំខាន់ ដែលមានបរិមាណសមាជិកគណបក្ស និងអង្គការចាត់តាំងគណបក្សចំណុះច្រើន ឬ ស្រុក-ខ័ណ្ឌដែលមានឃុំ-សង្កាត់ចំណុះ ចំនួន ១១ ឡើងទៅ ។

- ប្រភេទស្រុក-ខ័ណ្ឌ មធ្យមនិងតូច គឺស្រុក-ខ័ណ្ឌដែលមានឃុំ-សង្កាត់ចំណុះចំនួន ១០ ចុះ ។

បរិមាណសមាជិកគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ដែលរួមមាន ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និង សមាជិក ត្រូវបានកំណត់ដូចខាងក្រោម :

**១-គណៈកម្មាធិការគណបក្ស**

- ស្រុក-ខ័ណ្ឌធំ គណៈកម្មាធិការគណបក្សមានចំនួន ២៧ រូបចុះ ។
- ស្រុក-ខ័ណ្ឌមធ្យមនិងតូច គណៈកម្មាធិការគណបក្សមានចំនួន ២១ រូបចុះ ។

**២-គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស**

- ស្រុក-ខ័ណ្ឌធំ គណៈអចិន្ត្រៃយ៍ មានចំនួន ០៩ រូបចុះ ។
- ស្រុក-ខ័ណ្ឌមធ្យមនិង តូច គណៈអចិន្ត្រៃយ៍ មានចំនួន ០៧ រូបចុះ ។

**គ**- គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ និមួយៗត្រូវផ្អែកលើគោលការណ៍កំណត់ អំពីរចនាសម្ព័ន្ធអង្គការចាត់តាំង ដូចខាងលើនេះ និងផ្អែកលើលក្ខណៈពិសេសនៃមូលដ្ឋាន សំណូមពរការងារ និងលក្ខណៈសម្បត្តិមន្ត្រី ដើម្បីលើកសំណើរៀបចំសមាសភាពគណៈកម្មាធិការគណបក្ស គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សអោយបានសមស្រប ដោយធានាបាននូវនិរន្តរភាពការងារគណបក្ស នៅពេលមានការផ្លាស់ប្តូរអាណត្តិមន្ត្រីរាជការ ។

គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ និមួយៗ ត្រូវធ្វើការបែងចែកសមាជិកម្នាក់ៗក្នុងគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស អោយទទួលបន្ទុកចង្កោមការងារ ឬ ផ្នែកការងារនិមួយៗរបស់គណបក្ស និងទទួលបន្ទុកដឹកនាំការងារពង្រឹងគណបក្ស ការអនុវត្តនយោបាយរបស់គណបក្សនៅតាមការិយាល័យ អង្គភាពមូលដ្ឋាន ឃុំ-សង្កាត់និមួយៗអោយស្របតាមសភាពការណ៍ និងសំណូមពរភារកិច្ចជាក់ស្តែង ។

**ឃ**- ចំពោះសមាជិកគណៈកម្មាធិការគណបក្ស សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ដែលរៀបចំពីមុនមក ហើយមានការផ្លាស់ប្តូរ ឬផ្ទេរភារកិច្ចទៅកាន់មុខតំណែងដែលខុសពីរចនាសម្ព័ន្ធខាងលើ ត្រូវពិនិត្យសំរួលភារកិច្ចអោយស្របតាមសេចក្តីកំណត់នេះ ។

**III-របៀបរបបធ្វើការងារ**

**ក-គណៈកម្មាធិការគណបក្ស**

គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ដឹកនាំការងារគណបក្សថ្នាក់ខ្លួន ឆ្លងតាមរយៈសន្និបាត ឬប្រជុំពេញអង្គ ១ ខែម្តង ។ ការងារសំខាន់ ដែលត្រូវដាក់ជូនគណៈកម្មាធិការគណបក្សសំរេចរួមមាន :

១-ទិសដៅ ភារកិច្ចនយោបាយ គោលការណ៍ វិធានការណ៍ចាត់តាំងអនុវត្តសេចក្តីសំរេចចិត្ត គោលការណ៍សំខាន់ៗរបស់គណបក្សថ្នាក់លើ និងសេចក្តីសំរេចចិត្តមហាសន្និបាតថ្នាក់ខ្លួន ។

២-របាយការណ៍បូកសរុប វាយតំលៃសភាពការណ៍ការងារគណបក្សនិងទិសដៅភារកិច្ច ផែនការប្រចាំឆមាសប្រចាំឆ្នាំរបស់គណបក្សស្រុក-ខ័ណ្ឌ ។

៣-គោលការណ៍ថ្មីសំខាន់ ៗ អំពីការងាររបស់គណបក្ស ។

៤-សំណើរៀបចំ ឬ សំរួលភារកិច្ចសមាសភាពគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ។

៥-គោលការណ៍ និងសេចក្តីព្រាងខ្លឹមសារសំរាប់បើកមហាសន្និបាតគណបក្សស្រុក-ខ័ណ្ឌ តាមការណែនាំរបស់ថ្នាក់លើ ។

៦-បញ្ហាផ្សេងៗ ដែលភាគច្រើននៃសមាជិកអចិន្ត្រៃយ៍ មិនទាន់មានការឯកភាព និង ឃើញថាចាំបាច់ត្រូវលើកយកមកដាក់ជូនគណៈកម្មាធិការគណបក្សសំរេច ។

## ខ-គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ទទួលខុសត្រូវដឹកនាំការងារគណបក្ស ស្រុក-ខ័ណ្ឌ ក្នុងចន្លោះពេលពីសន្និបាតពេញអង្គមួយទៅសន្និបាតពេញអង្គមួយទៀតរបស់គណៈកម្មាធិការគណបក្ស ។ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ស្រុក-ខ័ណ្ឌ ១ ខែប្រជុំ ២ដង ក្នុងករណីចាំបាច់អាចប្រជុំមុនពេលកំណត់ ។

ការងាររបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សស្រុក- ខ័ណ្ឌ រួមមាន :

១ - ដឹកនាំ ណែនាំ ចាត់តាំងអនុវត្តសេចក្តីសំរេចចិត្តរបស់គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ និង គោលការណ៍កំណត់ទាំងឡាយរបស់គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ។

២-ដឹកនាំការងាររបស់បណ្តាគណៈ ផ្នែក និង ការិយាល័យ ចំណុះគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ។

៣-ដឹកនាំពង្រឹងអង្គការចាត់តាំងរបស់គណៈកម្មាធិការគណបក្ស និង សាខាចំណុះ និងការអនុវត្តន៍ភារកិច្ចការងារគណបក្ស ការងារពង្រឹងមូលដ្ឋាន និង ចលនាមហាជន ។

៤-សំរេចការងារមន្ត្រីដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ និងលើកសំណើរៀបចំមន្ត្រីគណបក្សក្នុងក្របខ័ណ្ឌស្រុក-ខ័ណ្ឌ ដែលស្ថិតក្នុងសមត្ថកិច្ចសំរេចរបស់ថ្នាក់ខេត្ត-ក្រុង ។

៥-អនុវត្តរបបរាយការណ៍តាមការកំណត់ជូនគណៈកម្មាធិការគណបក្សខេត្ត-ក្រុង និង ចាត់តាំងផ្សព្វផ្សាយសភាពការណ៍ ភារកិច្ចដល់គណៈកម្មាធិការគណបក្ស និង សាខាចំណុះ ។

៦-កោះប្រជុំ និង ត្រៀមរៀបចំខ្លឹមសារសន្និបាតឬប្រជុំពេញអង្គគណៈកម្មាធិការគណបក្ស និងរាយការណ៍ជូនគណៈកម្មាធិការគណបក្ស អំពីសភាពការណ៍ការងារដែលគណៈអចិន្ត្រៃយ៍បានសំរេច ។

## គ- ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស

- ប្រធានគណៈកម្មាធិការគណបក្ស ជាប្រធានគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ទទួលខុសត្រូវដឹកនាំរួមតាមគោលការណ៍ដែលបានសំរេចដោយគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ។

- គណៈកម្មាធិការគណបក្សមានអនុប្រធាន ១រូប ឬ ២ រូប ។ អនុប្រធាន ១ រូបត្រូវបានកំណត់ភារកិច្ចជាអនុប្រធានប្រចាំការ ទទួលបន្ទុកដោះស្រាយការងារប្រចាំថ្ងៃ និងចាត់តាំងអនុវត្តភារកិច្ចដែលគណបក្សស្រុក.ខ័ណ្ឌបានសំរេច

អនុប្រធានទទួលខុសត្រូវជួយប្រធានដឹកនាំការងារមួយចំនួនតាមការប្រគល់ភារកិច្ចរបស់ប្រធាន និងគណៈអចិន្ត្រៃយ៍ និងជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន ។

- សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស ស្រុក-ខ័ណ្ឌ ត្រូវក្តាប់នូវសេចក្តីសំរេចចិត្ត និងគោលការណ៍នានារបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ដើម្បីដឹកនាំ ណែនាំ និងចាត់តាំងអនុវត្តនៅតាមផ្នែកការងារ ឬ មូលដ្ឋាន ដែលខ្លួនទទួលខុសត្រូវ ។ ត្រូវកំណត់របបចុះជួយដល់មូលដ្ឋាន រួមចំណែកក្នុងការដឹកនាំការងារគណបក្សនិងការកសាងពង្រឹងគណបក្ស ស្វែងយល់សភាពការណ៍ ក្តាប់សំណូមពររបស់សមាជិកគណបក្ស និងមហាជន ដើម្បីលើកសំណើជូនគណៈអចិន្ត្រៃយ៍ និង គណៈកម្មាធិការគណបក្សចេញសេចក្តីសំរេចចិត្ត គោលការណ៍ វិធានការដឹកនាំរួម ។

- ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ដឹកនាំការងារគណបក្សតាមស្មារតីសំរេចនៃសមូហភាពគណៈអចិន្ត្រៃយ៍ ឬគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ។ នៅពេលពិភាក្សាការងារ ត្រូវគោរពមតិប្រជាធិបតេយ្យ ក្រោយពេលអនុម័ត ភាគតិចត្រូវគោរពភាគច្រើន ហើយត្រូវអនុវត្តតាមគោលការណ៍ដែលសមូហភាពបានសំរេច ។ ការអនុម័តរបស់គណៈអចិន្ត្រៃយ៍ និង គណៈកម្មាធិការគណបក្សកំណត់យកសំលេងភាគច្រើនដាច់ខាតនៃសមូហភាពគណៈអចិន្ត្រៃយ៍ទាំងមូល និង គណៈកម្មាធិការគណបក្សទាំងមូល លើកលែងតែការអនុម័តសំរេចការងារមួយចំនួនដែលមានការកំណត់ដោយឡែកក្នុងលក្ខន្តិកៈគណបក្ស ។

ខុទ្ទកាល័យ គណៈចាត់តាំងគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ និង គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីកំណត់នេះ ។

សេចក្តីកំណត់ដែលមានពីមុន ហើយផ្ទុយពីសេចក្តីកំណត់នេះត្រូវទុកជានិរាករណ៍ ។

ជ. គណៈអចិន្ត្រៃយ៍

ប្រធាន

ជា ស៊ីម

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ : ១០៣ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រិត និង វឌ្ឍនភាពសង្គម

ភ្នំពេញ , ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៧

# សេចក្តីណែនាំបន្ថែម
# ស្តីពីការរៀបចំរចនាសម្ព័ន្ធ និងបរិមាណ
# សមាជិកគណៈកម្មាធិការគណបក្សស្រុក ខណ្ឌ ឃុំ សង្កាត់

**យោង** : - លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស

- សេចក្តីកំណត់លេខ ៧៧ សណ.គក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សស្រុក ខណ្ឌ
- សេចក្តីណែនាំបន្ថែមលេខ៧៩ សណ.គក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ស្តីពីការរៀបចំរចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ សង្កាត់
- សំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្សនាដំណាក់កាលបច្ចុប្បន្ន
- ស្មារតីរបស់អង្គប្រជុំគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៧ ។
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល**

ណែនាំបន្ថែមស្តីពីការរៀបចំកែសម្រួល**រចនាសម្ព័ន្ធ និងបរិមាណ**សមាជិកគណៈកម្មាធិការគណបក្ស**ស្រុក ខណ្ឌ ឃុំ សង្កាត់** ដូចខាងក្រោម :

## ១-អំពីរចនាសម្ព័ន្ធ :

ការរៀបចំសមាសភាពនៃគណៈកម្មាធិការគណបក្ស**ស្រុក ខណ្ឌ ឃុំ សង្កាត់** ត្រូវបានកំណត់ឱ្យជ្រើសរើសបន្ថែមប្រធានគណៈកម្មាធិការគណបក្ស ឬប្រធានសាខាបក្សនៃអង្គភាពឈរជើងសំខាន់ៗក្នុង**ស្រុក ខណ្ឌ ឃុំ សង្កាត់** សាមីនិងជាអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

២-**អំពីបរិមាណ** :

**ក**-បរិមាណសមាជិកគណៈកម្មាធិការគណបក្ស **ស្រុក ខណ្ឌ ឃុំ សង្កាត់** ដែលរួមមាន ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ ត្រូវបានកែសម្រួលនិងកំណត់ដូចខាងក្រោម :

- ចំពោះ**ស្រុក ខណ្ឌធំ** សមាជិកគណៈកម្មាធិការគណបក្សស្រុក ខណ្ឌមានចំនួន**៣៧រូប**ចុះ ។
- ចំពោះ**ស្រុក ខណ្ឌ មធ្យមនិងតូច** សមាជិកគណៈកម្មាធិការគណបក្សស្រុក ខណ្ឌមានចំនួន**២៧រូប**ចុះ ។
- ចំពោះ**ឃុំ សង្កាត់ធំ** សមាជិកគណៈកម្មាធិការគណបក្សឃុំ សង្កាត់មានចំនួន**២៧រូប**ចុះ ។
- ចំពោះ**ឃុំ សង្កាត់ មធ្យមនិងតូច** សមាជិកគណៈកម្មាធិការគណបក្សឃុំ សង្កាត់ មានចំនួន**២១រូប**ចុះ ។

**ខ**-បរិមាណសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស **ស្រុក ខណ្ឌ ឃុំ សង្កាត់** ដែលរួមមាន ប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ ត្រូវបានកំណត់ឱ្យមានយ៉ាងច្រើនត្រឹម ***មួយភាគបី***នៃចំនួនសមាជិកគណៈកម្មាធិការគណបក្ស **ស្រុក ខណ្ឌ ឃុំ សង្កាត់** ទាំងមូល ។

**គ**-ចំពោះបរិមាណខាងលើនេះ ប្រសិនបើមុខសញ្ញាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេនោះ គឺមិនត្រូវបញ្ចូលឡើយ ទោះបីមុខសញ្ញានោះត្រូវតាមរចនាសម្ព័ន្ធក៏ដោយ ។

៣-ចំពោះសមាជិកគណៈកម្មាធិការគណបក្ស**ស្រុក ខណ្ឌ ឃុំ សង្កាត់** ដែលមានមន្ត្រីចូលនិវត្តន៍ គឺអាស្រ័យដោយគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស**ស្រុក ខណ្ឌ និង ខេត្ត ក្រុង** សាមីជាអ្នកសម្រេចរៀបចំប្រើប្រាស់តាមការជាក់ស្តែង ។

៤-បណ្តាចំណុចស្តីពីរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណៈកម្មាធិការគណបក្ស**ស្រុក ខណ្ឌ ឃុំ សង្កាត់** ដែលមានខ្លឹមសារខុសពីសេចក្តីណែនាំបន្ថែមនេះ ត្រូវទុកជានិរាករណ៍ ។

ខុទ្ទកាល័យ គណៈចាត់តាំងគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំបន្ថែមនេះ ។

**ជ.គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ជា ស៊ីម**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

លេខ: ១១៣ ...... សណ.គក

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩

# សេចក្តីណែនាំ

## ស្តីពីការពង្រីកបន្ថែមរចនាសម្ព័ន្ធ និងបរិមាណ សមាជិកគណៈកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ

**យោង** :
- សេចក្តីណែនាំបន្ថែមលេខ ១០២ សណ.គក ចុះថ្ងៃទី ២០-០៧-២០០៧ ស្តីពីការរៀបចំរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណកម្មាធិការគណបក្សខេត្ត-ក្រុង
- សេចក្តីណែនាំបន្ថែមលេខ ១០៣ សណ.គក ចុះថ្ងៃទី ៩-០៨-២០០៧ ស្តីពីការរៀបចំរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណកម្មាធិការគណបក្សស្រុក. ខណ្ឌ. ឃុំ. សង្កាត់
- សំណូមពរនៃការងាររបស់គណបក្សនៅក្នុងដំណាក់កាលថ្មី
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍ នៃគណកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីការពង្រីកបន្ថែមរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ដូចតទៅ :

១- ទន្ទឹមនឹងបន្តអនុវត្តតាមរចនាសម្ព័ន្ធចាស់ដែលមានរួចហើយ គណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ នីមួយៗ អាចពង្រីករចនាសម្ព័ន្ធរបស់ខ្លួនបន្ថែមទៀត នៅក្នុងជួរ**សមាជិកក្រុមប្រឹក្សារាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ** ដែលជាសមាជិកគណបក្សយើង និងជាអ្នកដែលមានលក្ខណៈសម្បត្តិសមស្របគ្រប់គ្រាន់ ។

២- ផ្អែកលើនេះ បរិមាណសមាជិកគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក ខណ្ឌ អាចកើនឡើងតាមជាក់ស្តែង ។ រីឯបរិមាណសមាជិកគណៈអចិន្ត្រៃយ៍នៃគណកម្មាធិការគណបក្សរាជធានី. ខេត្ត ក្រុង. ស្រុក. ខណ្ឌ ក៏អាចកើនឡើងដែរ តែកំណត់មិនអោយលើស ១/៣ នៃចំនួនសមាជិកគណកម្មាធិការគណបក្សរាជធានី ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ឡើយ ។

៣- ចំពោះសមាជិកក្រុមប្រឹក្សារាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ដែលកំពុងមានឋានៈនាទីនៅក្នុងគណកម្មាធិការគណបក្ស ឬក្នុងគណៈអចិន្ត្រៃយ៍នៃគណកម្មាធិការគណបក្សរាជធានី. ខេត្ត ក្រុង. ស្រុក ខណ្ឌ រួចហើយនោះ ត្រូវរក្សាទុកនៅដដែល លើកលែងតែមានករណីពិសេសដោយឡែក ។

៤- ចំពោះ**ប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ** ណាមួយដែលពុំមែនជាប្រធាន ឬអនុប្រធានគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ទេនោះ អាចស្នើសុំតែងតាំងជាអនុប្រធានគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ បន្ថែមម្នាក់ទៀតបាន ។

ទទួលបានសេចក្តីណែនាំនេះ ខុទ្ទកាល័យ គណៈចាត់តាំងគណកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណកម្មាធិការគណបក្សរាជធានី. ខេត្ត. ក្រុង. ស្រុក. ខណ្ឌ ត្រូវអនុវត្តអោយបានល្អប្រសើរ ទៅតាមគោលការណ៍ និងនីតិវិធីរបស់គណបក្សយើង ។

ជ.គណៈអចិន្ត្រៃយ៍

ប្រធាន

ជា ស៊ីម

**គណបក្សប្រជាជនកម្ពុជា**

គណៈកម្មាធិការកណ្តាល

**លេខ** ០៧/១៥ **សណ.គក**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ,ថ្ងៃទី១៣ខែមីនា ឆ្នាំ ២០១៥

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**យោង** : - សេចក្តីកំណត់លេខៈ ៦៥ សណ.គក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការ របស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត

- សេចក្តីកំណត់លេខៈ ៧៧ សណ.គក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការ របស់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ
- សេចក្តីណែនាំបន្ថែមលេខៈ ១១៣ សណ.គក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការពង្រីកបន្ថែមរចនាសម្ព័ន្ធ និងបរិមាណសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សំណូមពរនៃការងារគណបក្សក្នុងដំណាក់កាលថ្មី
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ណែនាំ**

អំពីការរៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដូចតទៅ :

**១**- ត្រូវបានកំណត់ជាគោលការណ៍ចំពោះការរៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**២**- ចំពោះអភិបាលខេត្ត ក្រុង ស្រុក ខណ្ឌ ដែលពុំមានតួនាទីជាប្រធានគណៈកម្មាធិការគណបក្សខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំតែងតាំងជាប្រធានគណៈកម្មាធិការគណបក្សខេត្ត ក្រុង ស្រុក ខណ្ឌ ។

**៣**- ចំពោះប្រធានគណៈកម្មាធិការគណបក្សខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នដែលមិនមែនជាអភិបាលខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំសម្រួលភារកិច្ច មកជាអនុប្រធានគណៈកម្មាធិការគណបក្សខេត្ត ក្រុង ស្រុក ខណ្ឌ វិញ ។

ទទួលបានសេចក្ដីណែនាំនេះ ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពតាមគោលការណ៍ និងនីតិវិធីរបស់គណបក្ស ។

ជ.គណៈអចិន្ត្រៃយ៍
ប្រធាន

ជា ស៊ីម

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**លេខៈ** ០៣/១៥ **សណ.គក**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ,ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥

# សេចក្តីណែនាំបន្ថែម
# ស្តីពី
# ការអនុវត្តគោលការណ៍រៀបចំប្រធានគណៈកម្មាធិការគណបក្ស រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**យោង** : -សេចក្តីណែនាំលេខ០២/១៥សណ.គកចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការរៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សំណូមពរនៃការងារគណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ណែនាំ**

អំពីការអនុវត្តគោលការណ៍រៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចតទៅ ៖

១.ការរៀបចំប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាគោលការណ៍រួមសម្រាប់ការពិនិត្យរៀបចំមន្ត្រីគណបក្ស ។

២.ចំពោះមុខនេះត្រូវពិនិត្យតាមករណីជាក់ស្តែងនីមួយៗ ចំពោះប្រធានក្រុមប្រឹក្សាដែលជាប្រធានគណៈកម្មាធិការគណបក្សខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្ន ដែលមានសុខភាពល្អ មានសមត្ថភាព និងមានប្រជាប្រិយភាពក្នុងការដឹកនាំ ត្រូវរក្សាទុកជាប្រធានគណៈកម្មាធិការគណបក្ស ។

៣.បន្ទាប់ពីបានយោបល់របស់ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយរាជធានី ខេត្ត គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវប្រជុំលើកសំណើរៀបចំប្រធានគណៈកម្មាធិការគណបក្ស ក្រុង ស្រុក ខណ្ឌ តាមសេចក្តីណែនាំនេះ ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ។

**ជ.គណៈអចិន្ត្រៃយ៍ ២**
**ប្រធាន**

**ជា ស៊ីម**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខៈ ០០១/២០ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃសុក្រ ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០២០

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំបន្ថែមប្រធានក្រុមប្រឹក្សា និងជាមេឃុំ ចៅសង្កាត់ ជាសមាជិកគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ

**យោង** : - សេចក្តីកំណត់លេខ ៧៧ សណ.គក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២
- សេចក្តីណែនាំបន្ថែមលេខ ១០៣ សណ.គក ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧
- សេចក្តីណែនាំលេខ ១១៣ សណ.គក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩
- សំណូមពរនៃការងារគណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០២០

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីការរៀបចំបន្ថែមសមាជិកគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌដូចខាងក្រោម ៖

ចំពោះឃុំ សង្កាត់ មួយចំនួនដែលបច្ចុប្បន្នប្រធានគណៈកម្មាធិការគណបក្សឃុំ សង្កាត់ ពុំមែនជាប្រធានក្រុមប្រឹក្សា និងជាមេឃុំ ចៅសង្កាត់ ចាំបាច់ត្រូវពិនិត្យរៀបចំបន្ថែមប្រធានក្រុមប្រឹក្សា និងជាមេឃុំ ចៅសង្កាត់ក្នុងតំណែងបច្ចុប្បន្ន ជាអនុប្រធានគណៈកម្មាធិការគណបក្សឃុំ សង្កាត់នោះ និងជាសមាជិកគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ១រូបទៀត ។

ខុទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ។

**ជ.គណៈអចិន្ត្រៃយ៍**
**អនុប្រធាន**

**សាយ ឈុំ**

**គណបក្សប្រជាជនកម្ពុជា**

គណៈកម្មាធិការកណ្តាល

លេខៈ០០៤/០៧២៥/សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃពុធ១៤កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០២៥

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំអនុប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**យោង** -សេចក្តីកំណត់លេខ ៦៥ សណ.គក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០០ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សខេត្ត ក្រុង

-សេចក្តីកំណត់លេខ ៧៧ សណ.គក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សស្រុក ខណ្ឌ

-សំណូមពរ និងភារកិច្ចរបស់គណបក្សនាដំណាក់កាលបច្ចុប្បន្ន

-ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១ខែកក្កដា ឆ្នាំ២០២៥

-មតិរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំបន្ថែមអំពីការរៀបចំអនុប្រធានគណៈកម្មាធិការគណបក្សរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

១-អនុប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងគណៈកម្មាធិការគណបក្ស ក្រុង ស្រុក ខណ្ឌ ជារួមត្រូវមានចំនួន ១ ទៅ ២រូប ។

២-ចំពោះរាជធានីភ្នំពេញ និងបណ្តាខេត្តកំពង់ចាម ព្រៃវែង កណ្តាល តាកែវ សៀមរាប កំពង់ស្ពឺ ស្វាយរៀង បាត់ដំបង កំពត កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង និងត្បូងឃ្មុំ អាចរៀបចំឱ្យមានអនុប្រធានគណៈកម្មាធិការគណបក្សចំនួន ៣រូប ។

៣-ចំពោះក្រុង ស្រុក ខណ្ឌ ដែលមានបរិមាណសមាជិកគណបក្សច្រើន និងមានអង្គការ

ចាត់តាំងគណបក្សចំណុះផ្ទាល់ចំនួន ១២ឡើងទៅ អាចរៀបចំឱ្យមានអនុប្រធានគណៈកម្មាធិការគណបក្សចំនួន ៣រូប ។

ខុទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ គណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ។

**ជ.គណៈអចិន្ត្រៃយ៍**
**ប្រធាន**

**ហ៊ុន សែន**